ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ:១១៨២/១២-១២-២០១២
សាលដីកា
លេខ:៣៨ក្រ.vត/៣០-០៥-២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍រឿងព្រហ្មទណ្ឌលេខ:១១៨២ ចុះថ្ងៃទី១២-១២-២០១២រវាង៖

១-ជនជាប់ចោទឈ្មោះ [redacted] ចំរើន ហៅប៊ុង ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ របររកស៊ីមិនពិតប្រាកដ មានទីកន្លែងកំណើត សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទីលំនៅសព្វថ្ងៃផ្ទះលេខ១ ផ្លូវលេខ [redacted] ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) នៅលីវ ទោសពីមុនគ្មាន។(ដើមបណ្តឹងឧទ្ធរណ៍)

មេធាវី លោក [redacted] រដ្ឋា

២-ជនជាប់ចោទឈ្មោះ [redacted] បូរី ភេទប្រុស អាយុ២០ឆ្នាំ ។

៣-ជនជាប់ចោទឈ្មោះ [redacted] លីណា ភេទស្រី អាយុ២០ឆ្នាំ ។

៤-ជនជាប់ចោទឈ្មោះ [redacted] ដានី ភេទស្រី អាយុ២៤ឆ្នាំ ។

ត្រូវចោទពីបទ: ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចសណ្ឋាគារ(ចកឃី) ក្នុងបន្ទប់លេខ២០១ ផ្លូវលេខ៦៣ កែងផ្លូវ ២១៤ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា៤២ កថាខណ្ឌទី១ និង មាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។/.

## ឯរឿងហេតុមានដូចតទៅៈ

តាមរបាយការណ៍របស់សមត្ថកិច្ចបញ្ជាក់ថា កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ វេលាម៉ោង ១៤និង១៥នាទី ជនសង្ស័យឈ្មោះ[redacted]បូរី ហៅ កណ្តុរ និង ឈ្មោះ[redacted]ចំរើន ហៅ ប៊ុន បានជិះម៉ូតូមួយគ្រឿងម៉ាកសេ១២៥ សេរី២០១២ ពណ៌ខ្មៅបានធ្វើសកម្មភាពឆក់ខ្សែករបស់ជនរងគ្រោះបានសម្រេចនៅចំណុចមុខស្ថានីយ៍ទូរទស្សន៍អប្សរាផ្លូវលេខ៣៦០ សង្កាត់បឹងកេងកងមួយ ខណ្ឌចំការមន រាជធានីភ្នំពេញ ហើយជនសង្ស័យបានជិះម៉ូតូគេចខ្លួនមកសណ្ឋាគារ(ចកឃី ) ឡើងទៅបន្ទប់លេខ២០១ ។ ក្រោយពីធ្វើសកម្មភាពឆក់ខ្សែកនេះ សមត្ថកិច្ចបានតាមដាននិងស្រាវជ្រាវរហូតដល់បានកំណត់មុខសញ្ញាថា ជនសង្ស័យទាំងពីរនាក់មានការពាក់ព័ន្ធនៅក្នុងបន្ទប់លេខ២០១នៃសណ្ឋាគារ(ចកឃី)នេះ ។ បន្ទាប់មកសមត្ថកិច្ចបានចូលធ្វើការត្រួតពិនិត្យក្នុងបន្ទប់លេខ២០១ នេះ មានឃើញមានជនសង្ស័យចំនួនពីរនាក់ទៀតគឺមានឈ្មោះ[redacted]ដានី និង ឈ្មោះ[redacted]លីណា និងបានដេកនៅក្នុងបន្ទប់នោះ រកឃើញថ្នាំញៀនចំនួនមួយកញ្ចប់ថង់តូច ទម្ងន់0,១១ក្រាម ប្រភេទម៉ាទឹកកក ដែលលាក់ទុកនៅក្រោមទូរស័ព្ទដាក់លើតុ និង កូនថង់ប្លាស្ទិកសម្រាប់ច្រកថ្នាំញៀនចំនួនមួយ ដែកកេះសម្រាប់ដុតជក់គ្រឿងញៀន និង សម្ភារៈវត្ថុតាងមួយចំនួនទៀត ដែលសមត្ថកិច្ចដកហូតបាន ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៧២"ខ" ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសលើៈ

ក/ ឈ្មោះ[redacted]បូរី ហៅ កណ្តុរ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ

ខ/ ឈ្មោះ[redacted] ចំរើន ហៅ ប៊ុង ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ

គ/ ឈ្មោះ [redacted]ដានី ភេទស្រី អាយុ២៤ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល ២៤ខែ (ម្ភៃបួនខែ ) តែទោសនេះត្រូវព្យួរជាពីរ គឺការអនុវត្តទោសពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល១៨ខែ(ដប់ប្រាំបីខែ)ចំណែកទោសដែលនៅសល់ត្រូវព្យួរធម្មតា។

ពីបទ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចសណ្ឋាគារ (ចកឃី) ក្នុងបន្ទប់លេខ២០១ ផ្លូវលេខ៦៣ កែងផ្លូវលេខ ២១៤ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា៤២ កថាខណ្ឌទី១ និង មាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ និងមាត្រា១០៦ មាត្រា១០៧ និង មាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ ។

២-អោយឈ្មោះ[redacted] លីណា ហៅ នូ ភេទស្រី អាយុ២៤ឆ្នាំ ជនជាតិខ្មែរ រួចផុតពីបទ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចសណ្ឋាគារ (ចកឃី) ក្នុងបន្ទប់លេខ២០១ ផ្លូវលេខ៦៣ កែងផ្លូវលេខ២១៤ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា៤២ កថាខណ្ឌទី១ និង មាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ និងបញ្ញត្តិមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣- ផ្តន្ទាទោសលើឈ្មោះ [redacted]លីណា ហៅ នូ ភេទស្រី អាយុ២៤ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល០៦ខែ(ប្រាំមួយខែ ) ពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចសណ្ឋាគារ (ចកឃី) ក្នុងបន្ទប់លេខ២០១ ផ្លូវលេខ៦៣ កែងផ្លូវលេខ ២១៤ សង្កាត់បឹងរាំង ខណ្ឌ

ដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤-ក/វត្ថុចាប់យកត្រូវរឹបអូសមាន៖

-ស្រោមសំបុត្រពណ៌សបិទជិតមានហត្ថលេខាសមត្ថកិច្ច និង មានស្នាមមេដៃរបស់ឈ្មោះ [redacted] លីណា ឈ្មោះ [redacted] ដានី ឈ្មោះ [redacted] បូរី និងឈ្មោះ [redacted] ចំរើន នៅលើស្រោមសំបុត្រមានសរសេរថា ៖ ក្រាមពណ៌សថ្លា ប្រភេទមេតំហ្វេតាមីនទម្ងន់0,០៩ ក្រាម ( សូន្យក្បៀសសូន្យប្រាំបួនក្រាម ) និង សំបកថង់ប្លាស្ទិកសម្រាប់ច្រកគ្រឿងញៀនចំនួន ០១ ។

-ដែកកេះពីរ (០២ ) ។

ខ/វត្ថុចាប់យកត្រូវប្រគល់ឲ្យម្ចាស់ដើមវិញមានដូចខាងក្រោម៖

-ទូរស័ព្ទដៃម៉ាកណូគា១២៨០ ពណ៌ខ្មៅ មួយគ្រឿង មានស៊ីម ។

-លុយចំនួន២០ដុល្លាអាមេរិក (ម្ភៃដុល្លារអាមេរិក )

-លុយខ្មែរចំនួន ២៤ 000រ (ពីរម៉ឺនបួនពាន់រៀល)

-កាបូបស្ពាយពណ៌ទឹកក្រូចមួយ ។

- អាយផេតពណ៌ទឹកប្រាក់មួយគ្រឿង ៣២G

- ទូរស័ព្ទដៃម៉ាក អ៊ិលជី ពណ៌ស មានស៊ីម

- ទូរស័ព្ទដៃម៉ាកណូគាអ៊ិច១ ពណ៌ខ្មៅមួយគ្រឿង មានស៊ីម

-ទូរស័ព្ទដៃម៉ាកណូគាសេ២ពណ៌ឈាមជ្រូកមួយគ្រឿង មានស៊ីម

-ប្រាក់ដុល្លារអាមេរិកចំនួន ៤៥00ដុល្លារអាមេរិក (បួនពាន់ប្រាំរយដុល្លារអាមេរិច )។

-ប្រាក់ខ្មែរចំនួន ១៤៤000 (ដប់បួនម៉ឺនបួនពាន់រៀល )

កាបូបពណ៌សមួយ ,អត្តសញ្ញាណប័ណ្ណមួយសន្លឹក ,កាតATMមួយ និង សៀវភៅធនាគារមួយក្បាល ។

-កាបូបស្បែកស្ពាយពណ៌ក្រម៉ៅមួយ ។

៥-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] បូរី ហៅកណ្តុរ ,ឈ្មោះ [redacted] ចំរើន ហៅ ប៊ុង ,ឈ្មោះ [redacted] លីណា ហៅ នូ ,ឈ្មោះ [redacted] ដានី និងមេធាវីការពារជនជាប់ចោទលោក [redacted] អ៊ួង ,លោក [redacted] ជីវរង និង លោក [redacted] វណ្ណាឌី និង ប្រកាសជាសាធារណៈ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០១-១១-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ចំរើនសុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ៧២"ខ" ចុះថ្ងៃទី២២-១០-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច សេចក្តីសម្រេចទាំងមូល ។

-បានឃើញរបាយការណ៍ ចុះថ្ងៃទី២៨-០២-២០១៣ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

**<u>ឆាពេលសវនាការ</u>**

-ជនជាប់ចោទឈ្មោះ [redacted] ចំរើន (អវត្តមាន)

ប្រធានក្រុមប្រឹក្សាៈបញ្ជាក់អង្គហេតុនៃរឿង

មេធាវីថ្លែងហេតុៈនៅថ្ងៃទី១២-៥-២០១២ ឈ្មោះ [redacted] ដានី បានទូរសព្ទ័ហៅកូនក្តីខ្លួនឲ្យមកជក់គ្រឿងញៀន ដោយថ្នាំញៀនជារបស់ឈ្មោះ [redacted] ដានី ទីកន្លែងប្រើប្រាស់ក៏ [redacted] ដានី ជាអ្នកជួល ហើយថ្នាំញៀនមានចំនួនតិចតួចទម្ងន់០,១១ក្រាមប៉ុណ្ណោះ ។ កូនក្តីខ្លួនគ្រាន់តែប្រើប្រាស់មិនបានចាត់ចែងទេ ហើយពេលនេះកូនក្តីខ្លួនបានដឹងពីកំហុស សុំកែប្រែខ្លួន និងសំណូមពរតុលាការមេត្តាបន្ធូរបន្ថយទោស។

តំណាងមហាអយ្យការផ្តល់សេចក្តីសន្និដ្ឋានៈ

-ក្រោយពីបានស្តាប់របាយការណ៍និងពិនិត្យចម្លើយជនជាប់ចោទបានឆ្លើយ និងចម្លើយជនជាប់ចោទ ៣នាក់ទៀតមានលក្ខណៈស៊ីសង្វាក់គ្នា ដូចមេធាវីលើកឡើងថា កូនក្តីគាត់មិនមែនជាអ្នកចាត់ចែងឲ្យប្រើប្រាស់គ្រឿងញៀនទេ សុំក្រុមប្រឹក្សាពិនិត្យលើអង្គហេតុ និងពិចារណាលើសេចក្តីសំរេចឡើងវិញ ។

- មេធាវីផ្តល់សេចក្តីសន្និដ្ឋានៈ

កូនក្តីខ្លួនមិនមែនជាអ្នកចាត់ចែងឲ្យប្រើប្រាស់គ្រឿងញៀនទេ គាត់គ្រាន់តែបានចូលរួមប្រើប្រាស់គ្រឿងញៀនប៉ុណ្ណោះ ហើយកូនក្តីខ្លួនជាសិស្សសុំក្រុមប្រឹក្សាមេត្តាអនុញ្ញាតឲ្យគាត់បានចូលរួមក្នុងសង្គមវិញផង ដោយគាត់សន្យាធ្វើការកែប្រែខ្លួន។

-ក្រោយពីបានស្តាប់ការអានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាល្អិតល្អន់ត្រឹមត្រូវតាមច្បាប់ហើយ។

## យល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០២-១១-២០១២របស់ជនជាប់ចោទឈ្មោះ [redacted] ចំរើន ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៧២ "ខ" ចុះថ្ងៃទី២២-១០-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេចធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន។

២-ជនជាប់ចោទត្រូវបានឃាត់ខ្លួនជាក់ស្តែងនៅកន្លែងកើតហេតុមានគ្នា៣នាក់ និងដកហូតថ្នាំញៀនបានមួយកញ្ចប់ ព្រមទាំងប្រដាប់ជក់គ្រឿងញៀន ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើដូចការចោទប្រកាន់ ។

៣-ជនជាប់ចោទប្តឹងសុំបន្ធូរបន្ថយទោសដើម្បីបានបន្តការសិក្សា ឃើញថាគប្បីតុលាការពិចារណាលើការប្តឹងសុំរបស់ជនជាប់ចោទ ដោយសំអាងលើយុវភាពរបស់ជនជាប់ចោទ លទ្ធភាពបន្តការសិក្សា និងចំនួនគ្រឿងញៀនមានតិចតួច ។

៤-សាលក្រមព្រហ្មទណ្ឌលេខ ៧២ "ខ" ចុះថ្ងៃទី២២-១០-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញបានសម្រេចត្រឹមត្រូវហើយ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមខាងលើទុកជាបានការ លើកលែងតែចំណុចដូចបានសំអាងហេតុទី៣ខាងលើ ដែលត្រូវកែតម្រូវឡើងវិញ។

## ឧនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០២-១១-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ចំរើន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៧២ "ខ" ចុះថ្ងៃទី២២-១០-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ លើកលែងតែចំណុចទី១-ខ នៃសេចក្តីសម្រេចត្រង់ "ផ្តន្ទាទោសជនជាប់ឈ្មោះ [redacted] ចំរើន ដាក់ពន្ធនាគារ២៤ខែ តែទោសនេះត្រូវញែកជាពីរ គឺការអនុវត្តទោសពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល១៨ខែ ចំណែកទោសដែលនៅសល់ត្រូវព្យួរធម្មតា " ត្រូវកែប្រែជា " ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ចំរើន ដាក់ពន្ធនាគារ២៤ខែ តែទោសនេះត្រូវញែកជាពីរ គឺការអនុវត្តទោសពន្ធនាគាររយៈពេល៧ខែ (ប្រាំពីរខែគត់) ចំណែកទោសដែលនៅសល់ព្យួរធម្មតា "។

ចំណុចដទៃទៀតនៃសេចក្តីសម្រេចនៅរក្សាទុកជាបានការដដែល។

៣-បន្តឃុំខ្លួនជនជាប់ចោទខាងលើតាមនីតិវិធី។

សាលដីកានេះ ជំនុំជំរះចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ចំរើន ប្រកាសជាសាធារណៈនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ បើកសិទ្ធិប្តឹងទាស់ និង ប្តឹងសាទុក្ខក្នុងរយៈពេលដែលច្បាប់កំណត់។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និង ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] , [redacted] | ហត្ថលេខា: [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ,ថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០១៤
ក្រឡាបញ្ជី

[redacted]

May 2011
March 2014